

**text** lis meyers
**photography** thomas angus

# The House That Flew

## ផ្ទះដែលបានហោះ

Darryl Collins's new home sits 2 kilometres from central Siem Reap facing a small canal. Yet in early 2006 the house had been located on a tiny island off Kampong Cham. "Impossible," one might say. But while this house did not fly, it was floated, boated, driven, and carried to its new home.

ផ្ទះថ្មីរបស់លោក ដារីល ខូលីន មានចម្ងាយ២គីឡូម៉ែត្រពីទីរួមខេត្តសៀមរាប បែរមុខទៅព្រែកតូចមួយ។ ប៉ុន្តែកាលពីដើមឆ្នាំ២០០៦ ផ្ទះនេះស្ថិតនៅលើកោះតូចមួយនៅខេត្តកំពង់ចាមឯណោះ។ គេអាចនិយាយថា "មិនអាចទៅរួចទេ"។ ប៉ុន្តែ ខណៈពេលដែលផ្ទះនេះមិនបានហោះនោះ វាត្រូវបានគេបណ្តែតទឹក ដឹកតាមទូក និងដឹកតាមឡានទៅកាន់ទីតាំងថ្មីនេះ។

Architect Hok Sokol initially came across the house in 2003 while doing research for a book on traditional, Cambodian, wooden houses. The same family had inhabited the structure for 80 to 90 years and three generations. Constructed with five different types of Khmer timber, it was built in the rare style of Phteah Rang Daol, possessing a long protruding roof that extends from the house onto the veranda, instead of the more common right-angled Khmer roof. With exquisite detailing and carving, Sokol knew that it was quite special.

Two years later, the house's owner contacted Sokol and asked if he wanted to buy it, warning that otherwise the house would have to be destroyed. Sokol had been aware that his friend, Darryl Collins, had been looking to move. Darryl, an Australian art historian, was an avid admirer of Khmer architecture. He had co-authored a book on Khmer architecture of the 1960s which Sokol had assisted on. When Darryl saw the house and instantly wanted it for his own, Sokol realized there was no choice but to transport it.

ស្ថាបត្យករ ហុក សុកល ឃើញផ្ទះនេះជាលើកដំបូងនៅឆ្នាំ២០០៣ ខណៈពេលកំពុងធ្វើការស្រាវជ្រាវសម្រាប់សៀវភៅមួយក្បាលស្តីពីផ្ទះខ្មែរបុរាណដែលធ្វើពីឈើ។ មនុស្សបីជំនាន់ក្នុងគ្រួសារតែមួយបានរស់នៅក្នុងផ្ទះនេះអស់រយៈពេលពី៨០ទៅ៩០ឆ្នាំ។ សាងឡើងដោយឈើខ្មែរប្រាំប្រភេទ ផ្ទះនេះកសាងជារចនាបថផ្ទះរោងដៀលដ៏កម្រមួយ ដែលមានដំបូលលយចេញយ៉ាងវែងមកលើរានហាល ខុសពីដំបូលខ្មែរទូទៅដែលកែងនៅជ្រុងខាងស្តាំ។ ជាមួយនឹងក្បាច់រចនាលម្អិត លោក សុកល ដឹងថា វាពិសេសខ្លាំងណាស់។

ពីរឆ្នាំក្រោយមក ម្ចាស់ផ្ទះនេះបានទំនាក់ទំនងមកលោក សុកល ហើយសួរថា តើគាត់ចង់ទិញផ្ទះនេះទេ ដោយប្រាប់ថា បើមិនដូច្នោះទេ ផ្ទះនេះនឹងត្រូវគេកម្ទេចចោលហើយ។ លោក សុកល ដឹងថា មិត្តភ័ក្ររបស់គាត់ លោក ដារីល ខូលីន កំពុង តែចង់ផ្លាស់ទីលំនៅ។ លោក ដារីល ដែលជាប្រវត្តិវិទូសិល្បៈអូស្ត្រាលី គឺជាអ្នកកោតសរសើរស្រលាញ់ស្ថាបត្យកម្មខ្មែរដ៏ខ្លាំងក្លាម្នាក់។ លោកបាននិពន្ធរួមគ្នានូវសៀវភៅមួយក្បាលស្តីពីស្ថាបត្យកម្មខ្មែរនាទសវត្សរ៍ទី៦០ ដែលលោក សុកល បានជួយក្នុងការងារនេះ។ នៅពេលដែលលោក ដារីល ឃើញផ្ទះនេះ ហើយភ្លាមៗចង់បានវាជាកម្មសិទ្ធិ លោក សុកល ដឹងថា គ្មានជម្រើសទេ ក្រៅពីដឹកវា។



